## III- ការងារបណ្ណាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សេចក្តីប្រកាស

ភ្នំពេញ,ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

## សេចក្តីប្រកាស លេខ ០២២ សប្រក.កសក

## ស្តីពី

## ការហាមឃាត់រាល់សកម្មភាពអាជីវកម្ម ពាណិជ្ជកម្មព្រៃឈើ ការកាប់រានដីព្រៃ និងការបរបាញ់សត្វព្រៃក្នុងតំបន់ជួរភ្នំក្រវាញភាគកណ្តាល

ដោយផ្អែកតាមលទ្ធផលរបាយការណ៍ ចុះសិក្សាស្រាវជ្រាវរបស់នាយកដ្ឋានរុក្ខា-ប្រមាញ់ សហការជាមួយអង្គការមូលនិធិសត្វខ្លា (CAT) ឆ្នាំ ១៩៩៨ អង្គការរុក្ខជាតិ និងរុក្ខជាតិអន្តរជាតិ (FFI) ឆ្នាំ ១៩៩៩ និង ២០០០ បានបង្ហាញយ៉ាងច្បាស់ថា តំបន់ជួរភ្នំក្រវាញពិតជាមានសក្តានុពលខ្ពស់សំរាប់ការអភិរក្សជីវចំរុះដូចជា : សត្វចតុប្បាទ (សត្វខ្លាធំ ខ្លាឃ្មុំ ដំរី ....) ឧរង្គសត្វ ក្រពើ ពស់ បង្គួយ ......បក្សីសត្វ និងប្រភេទរុក្ខជាតិមានដោយកម្រផ្សេងៗទៀត ព្រមទាំងប្រព័ន្ធផ្លូវទឹក និង បណ្តាតំបន់ទឹកជ្រោះដ៏មានតំលៃធំធេងដែលរួមផ្សំគ្នាបង្កើតបានជាប្រព័ន្ធអេកូឡូស៊ីមួយដ៏ប្រណិត ។ ទន្ទឹមនឹងនេះដែរផ្អែកតាមរបាយការណ៍របស់គំរោងត្រួតពិនិត្យ និងតាមដានឧក្រិដ្ឋកម្មព្រៃឈើ បានបញ្ជាក់ថា ភាពអនាធិបតេយ្យ ក្នុងការធ្វើអាជីវកម្មព្រៃឈើ និងការលួចបរបាញ់សត្វព្រៃក្នុងជុំវិញតំបន់នោះបាននឹងកំពុងគំរាមកំហែងយ៉ាងធ្ងន់ធ្ងរ ។ ការបាត់បង់ព្រៃឈើអាចនឹងជះឥទ្ធិពលយ៉ាងខ្លាំងក្លាទៅលើតុល្យភាពប្រព័ន្ធអេកូឡូស៊ីកសិកម្ម និងជីវសាស្ត្រចំរុះក្នុងប្រទេសកម្ពុជា និងដោយការមើលឃើញនូវភាពចាំបាច់ និងតួនាទីដ៏មានសារៈសំខាន់របស់តំបន់ភាគកណ្តាលនៃជួរភ្នំក្រវាញ ក្នុងការថែរក្សាលំនឹងបរិស្ថានធម្មជាតិ ជាពិសេស ដើម្បីការពារនូវពពួកសត្វព្រៃមួយចំនួនដែលកំពុងទទួលរងនូវការគំរាមកំហែងស្ទើរលត់ផុតពូជពីលើភពផែនដី ប៉ុន្តែកំពុងមានវត្តមានក្នុងតំបន់នេះ រាជរដ្ឋាភិបាលបានអនុញ្ញាតឱ្យ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើសេចក្តីប្រកាសដូចតទៅ :

១-កំណត់តំបន់ជួរភ្នំក្រវាញភាគកណ្តាល ជាតំបន់សិក្សាស្រាវជ្រាវ ដើម្បីកំណត់ទិសដៅ និងផែនការគ្រប់គ្រងអភិរក្សជីវចំរុះ និងភាពបរិសុទ្ធនៃធម្មជាតិ ។

២-កំណត់តំបន់ជួរភ្នំក្រវាញភាគកណ្តាលនេះមានផ្ទៃដីសរុបចំនួន ៣៣០.៩២៣ ហិកតា មានព្រំប្រទល់ដូចបានកំណត់នៅលើផែនទីជូនភ្ជាប់ជាមួយនេះ ។

៣-ហាមដាច់ខាតរាល់សកម្មភាពអាជីវកម្ម ពាណិជ្ជកម្មព្រៃឈើ ការកាប់រានដីព្រៃឈើ ការរុករាន ការបំផ្លាញព្រៃឈើ និងការបរបាញ់សត្វព្រៃនៅតំបន់ជួរភ្នំក្រវាញភាគកណ្តាលនេះ ។

៤-មិនហាមឃាត់ និងប៉ះពាល់ដល់សិទ្ធិរបស់ប្រជាជនដែលរស់នៅក្នុង និងជុំវិញតំបន់ជួរភ្នំក្រវាញ ដើម្បីប្រមូលអនុផលព្រៃឈើសំរាប់ប្រើប្រាស់ និងតម្រូវការនៅមូលដ្ឋានទេ ។

៥ ក្រុមហ៊ុនព្រៃសម្បទានទាំងអស់ដែលមានផ្ទៃដីស្ថិតនៅក្នុងតំបន់សិក្សានេះ ត្រូវផ្អាកជាបណ្តោះអាសន្ននូវគ្រប់សកម្មភាពអាជីវកម្មព្រៃ ដើម្បីផ្តល់លទ្ធភាពដល់ការសិក្សាស្រាវជ្រាវលំអិត ។

៦ ព្រំប្រទល់តំបន់ព្រៃឈើនេះ អាចធ្វើការកែប្រែតាមការចាំបាច់ ដោយផ្អែកលើលទ្ធផល ពត៌មានវិទ្យាសាស្ត្រ និងស្ថានភាពចាំបាច់ជាក់ស្តែងនាពេលអនាគត ។

ក្រោយពីទទួលសេចក្តីប្រកាសនេះ គ្រប់អង្គភាពនៅថ្នាក់កណ្តាល ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មន្ទីរកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ការិយាល័យរុក្ខា-ប្រមាញ់ ខេត្តពោធិសាត់ កោះកុង និង កំពង់ស្ពឺ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ និង ខិតខំអនុវត្តន៍សេចក្តីប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់បំផុត ។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ចំន្ទ គុនអ៊ីច**

****